ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៧៨០៨ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញា
## រដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្តាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកណ្តាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតនិមិត្តសញ្ញារដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្តាល មានរូបរាង ប្រភេទ និងលក្ខណៈសម្គាល់ដូចខាងក្រោម៖

- និមិត្តសញ្ញាមានរាងមូលព័ទ្ធដោយខ្សែវណ្ណខាងក្រៅពណ៌មាស ខាងក្នុងព័ទ្ធដោយផ្កាវដ្ដិលពណ៌មាស និងខ្សែវណ្ណខាងក្នុងពណ៌មាស បង្ហាញអំពីផាសុកភាព បរិស្ថានស្អាត និងការគ្រប់គ្រងដែនដីរបស់រដ្ឋបាលស្រុក
- ព្រះព្រហ្មមុខបួននិងព្រះហស្តបួនមានពណ៌សស្រគាំ ព្រះសីសៈមានឈ្នួតពណ៌មាស គង់លើបល្ល័ង្កពណ៌ត្នោត ជាតំណាងនៃទេវតាពួកព្រហ្មក្នុងជំនឿសាសនាដែលត្រូវបានប្រជាជនគោរពបូជាក្នុងជំនឿព្រហ្មញ្ញ ឬសាសនាព្រាហ្មណ៍តាំងពីបុរាណ នៅតាមស្ថានីយមួយចំនួនក្នុងស្រុកអង្គស្នួល។ ព្រះព្រហ្មមុខបួន បង្ហាញអំពីព្រហ្មវិហារធម៌មានមេត្តា ករុណា មុទិតា និងឧបេក្ខា ហើយមានព្រះហស្តបួននៅខាងស្ដាំពីរនិងឆ្វេងពីរ។ ព្រះហស្តស្ដាំខាងលើកាន់ផ្គាំពណ៌មាស បង្ហាញអំពីភាពអត់ធ្មត់ ព្យាយាម សេចក្ដីចម្រើន និងអំពើល្អ ហើយព្រះហស្តស្ដាំខាងក្រោមកាន់ពួចទឹកពណ៌មាស បង្ហាញអំពីទឹកអម្រឹតសម្រាប់សេចក្ដីសុខ សន្តិភាព និងភាពត្រជាក់ត្រជុំ។ ព្រះហស្តឆ្វេងខាងលើកាន់ផ្កាឈូកពណ៌មាស បង្ហាញអំពីការគោរពបូជាចំពោះជំនឿផ្សេងៗ ហើយព្រះហស្តឆ្វេងខាងក្រោមកាន់គម្ពីរពណ៌មាស បង្ហាញអំពីក្បួនច្បាប់និងសាស្ត្រាខ្មែរ
- ដើមត្នោតបីដើមមានស្លឹកពណ៌បៃតងស្រស់ បង្ហាញអំពីរុក្ខជាតិនិមិត្តរូបជាតិខ្មែរមួយប្រភេទ ដែលផ្ដល់អត្ថប្រយោជន៍ទាំងផ្លែ ដើម និងស្លឹកសម្រាប់ប្រកបមុខរបរតាមប្រពៃណីរបស់ប្រជាជនតាំងពីសម័យបុរាណរហូតដល់សព្វថ្ងៃនេះ
- ដើមស្នួលមួយដើមមានស្លឹកពណ៌បៃតងខ្ចី បង្ហាញអំពីឈើមួយប្រភេទដែលដុះនៅក្នុងស្រុក ឬភូមិតាំងពីសម័យដើមរហូតដល់បច្ចុប្បន្ន
- ផ្លូវថ្នល់ បង្ហាញអំពីការរីកចម្រើន និងទំនាក់ទំនងនៃគមនាគមន៍ផ្លូវគោក
- ផ្ទៃក្រឡាចត្រង្គខ្វាត់ខ្វែងពណ៌បៃតង បង្ហាញអំពីវាលស្រែសម្រាប់ផលិតផលដំណាំស្រូវ បន្លែបង្ការ និងដំណាំផ្សេងទៀត
- អក្សរឈ្មោះ«រដ្ឋបាលស្រុកអង្គស្នួល»មានពណ៌ស រំលេចក្នុងខ្សែបូពណ៌ក្រហមអមដោយខ្សែបូពណ៌ខៀវ
- ផ្ទៃពណ៌ស បង្ហាញអំពីភាពជឿជាក់ ភាពស្មោះត្រង់ និងភាពត្រជាក់ត្រជុំ។

**ប្រការ២ .-**

ត្រូវបានដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្ដាល ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

និមិត្តសញ្ញារដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្ដាល ត្រូវប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការងារនៅរដ្ឋបាលស្រុកអង្គស្នួល
- ប្រើប្រាស់នៅលើលិខិត ស្រោមសំបុត្រ និងឯកសារផ្លូវការពាក់ព័ន្ធរបស់រដ្ឋបាលស្រុកអង្គស្នួល
- ប្រើប្រាស់ក្នុងពិធីនានា និងប្រើប្រាស់ក្នុងកិច្ចការជាផ្លូវការផ្សេងៗតាមការចាំបាច់។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានមនុស្ស ប្រធានអង្គភាព

ផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សាខេត្តកណ្តាល អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ប្រធានក្រុមប្រឹក្សាស្រុកអង្គស្នួល និងអភិបាលនៃគណៈអភិបាលស្រុកអង្គស្នួល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...ចន្ទ ១៣កើត...... ខែ.បឋមាសាឍ.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៧....ខែ..វិច្ឆិកា........ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលខេត្តកណ្តាល
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ...៣៤០៨...ប្រក ចុះថ្ងៃ...ចន្ទ ១រោច.........ខែ...មិគសិរ..... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី...១២....ខែ...ធ្នូ......ឆ្នាំ២០២៤ ស្តីពីការបង្កើត និងការដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញារដ្ឋបាលស្រុកអង្គស្នួល ខេត្តកណ្តាល។

## និមិត្តសញ្ញារដ្ឋបាលស្រុកអង្គស្នួល